បេសកកម្មនេះ ក្រោមបញ្ជាអាជ្ញាធរ ដូចមានចែងក្នុងវគ្គ “ គ ” នៃមាត្រា ៤ នៃអនុក្រឹត្យនេះ ។

**មាត្រា១៣:** អធិការ ឬ នាយកកងអាវុធហត្ថអាចស្នើបង្កើតនូវអង្គភាពឯកទេសផ្សេងៗទៀត ដើម្បីប្រសិទ្ធភាពការងារក្នុងកាលៈទេសៈចាំបាច់ ។

**មាត្រា១៤:** ប្រគល់ជូនសហរដ្ឋមន្ត្រីការពារជាតិ និង នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ នូវនាទីកំណត់ភារកិច្ច ចំនួនជាក់ស្តែងនិងការស្នើតែងតាំង ក្នុងការរៀបចំស្ថាប័ន ដែលមានចែងខាងលើ ដោយមានការពិគ្រោះយោបល់ជាមួយសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា១៥:** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយអំពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១៦:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និងគ្រប់ក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង កុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៤

## អនុក្រឹត្យលេខ ២៦ អនក្រ
## ស្តីពី និយ័ត្តភាពសណ្ឋានរបស់
## ក្រសួងមហាផ្ទៃ ពីជំពូក ១១ មកជំពូក ១២

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះ

មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ :** ថវិការបស់ក្រសួងមហាផ្ទៃ សំរាប់ឆ្នាំ ១៩៩៤ ត្រូវបានកែសំរួលដោយធ្វើនិយត្តកម្មដូចតទៅ ÷

- ផ្នែកទី ១ : សន្តិសុខសាធារណៈ
- ប្រភេទ ១ : មធ្យោបាយសេវា
- ជំពូក ១១ : ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច

និយត្តភាពបញ្ចូលទៅ :

- ផ្នែកទី ២ : រដ្ឋបាលទូទៅ
- ប្រភេទ ១ : មធ្យោបាយសេវា
- ជំពូក ១២ : ប្រាក់ឧបត្ថម្ភ សំរាប់ដំណើរការ អង្គការសាធារណៈ រដ្ឋបាល
- ទឹកប្រាក់បន្ថែម : ៣៩៤៦.៣១៦.០០០ រៀល ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| --- | --- |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |